


សុវត្ថិភាពពិតប្រាកដ



(15)

នេះគឺជាពាក្យរបស់លោក ដេវេក ព្រីនស៍
ដែលបានដកស្រង់ពីព្រះបន្ទូលនៃព្រះសម្រាប់លោកអ្នក។

> ត្បិត ឱព្រះយេហូវ៉ាអើយ
> ទ្រង់នឹងប្រទានពរដល់មនុស្សសុចរិត
> ទ្រង់នឹងបាំងអ្នកទាំងនោះនៅជុំវិញ ដោយព្រះគុណ
> ទុកដូចជាខែល។ [ទំនុកដំកើង ៥:១២]

នេះហើយជារឿងមួយដែលប្រាកដណាស់ថា
ព្រះអម្ចាស់ប្រទានពរដល់មនុស្សសុចរិត។
រឿងជាច្រើននៅថ្ងៃនេះដែលយើងធ្លាប់បានពឹងពាក់
យើងបានឃើញថា វាមិនមានភាពប្រាកដប្រជាទាំងស្រុងនោះទេ។
កន្លែងជាច្រើនដែលយើងបានស្វែងរកសន្តិសុខ
និងភាពច្បាស់លាស់បានធ្វើឱ្យយើងបរាជ័យ និងធ្វើឱ្យយើងធ្លាក់ចុះ។
ដំណោះស្រាយនយោបាយ
និងដំណោះស្រាយហិរញ្ញវត្ថុហាក់បីដូចជាកំពុងតែដួលរលំនៅពេលសព្វថ្ងៃនេះ។ ប៉ុន្តែមានរឿងមួយដែលនៅតែប្រាកដនៅក្នុងជីវិត គឺថា
ព្រះអម្ចាស់ប្រទានពរដល់មនុស្សសុចរិត។

យើងត្រូវចំណាយពេលកាន់តែច្រើនថែមទៀតគិតអំពីការធ្វើឱ្យប្រាកដ
ថា ជីវិតរបស់យើង គឺបានត្រឹមត្រូវនៅចំពោះព្រះអម្ចាស់
ថាយើងសក្តិសមចំពោះព្រះពររបស់ព្រះអម្ចាស់
ដែលទ្រង់បម្រុងទុកសម្រាប់មនុស្សសុចរិត
ដែលនេះគ្រាន់តែសម្រាប់មនុស្សសុចរិតប៉ុណ្ណោះ។

ហើយបន្ទាប់មកអ្នកនិពន្ធទំនុកដំកើងនិយាយថា៖
«ទ្រង់នឹងបាំងអ្នកទាំងនោះ (មនុស្សសុចរិត) នៅជុំវិញ
ដោយព្រះគុណ ទុកដូចជាខែល»។

ព្រះគុណរបស់ព្រះគឺសម្រាប់មនុស្សសុចរិត។
នៅពេលដែលយើងដើរនៅក្នុងសេចក្តីសុចរិតរបស់ទ្រង់
ព្រះគុណរបស់ទ្រង់គឺដូចជាខែល
ការពារនៅជុំវិញយើងទប់ទល់នឹងការវាយប្រហារដល់ជីវិតយើង។

វាការពារយើងប្រឆាំងនឹងសេចក្តីស្លាប់។
វាការពារយើងប្រឆាំងនឹងអំណាចដែលខ្លាំងពេកសម្រាប់យើង។
វាការពារយើងពីគ្រោះអន្តរាយ និងគ្រោះថ្នាក់ និងអំពើអាក្រក់។
នេះជាព្រះពរមួយក្នុងការដើរដោយព្រះគុណរបស់ព្រះអម្ចាស់
ដោយដឹងពីព្រះវត្តមានរបស់ទ្រង់
ដោយដឹងពីព្រះគុណរបស់ទ្រង់នៅបាំងជុំវិញអ្នកដូចជាខែល។
សូមចាំថាមានរឿងមួយដែលប្រាកដគឺព្រះអម្ចាស់ប្រទានពរដល់មនុស្សសុចរិត។

© 1970 — Derek Prince Ministries - International®

: WD-WFTW-015-KHM
: 24 Feb 2026
: derekprince.com/km/resources

